# ធនាគារ អេស៊ីលីដា ភីអិលស៊ី
## ACLEDA Bank Plc.

# សេចក្តីជូនដំណឹង
## ស្តីពី
## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (ធ.អ.ក)

ធនាគារ អេស៊ីលីដា **ភីអិលស៊ី** ("ធ.អ.ក") មានកិត្តិយសសូមជម្រាបជូនភាគហ៊ុនិកទាំងអស់ទទួលជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ធ.អ.ក នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក នៅការិយាល័យកណ្តាលធនាគារ ជាន់ទី៦ និងជាន់ទី៧ ដែលមានទីតាំងស្ថិតនៅអគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក រាជធានីភ្នំពេញ **នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៤:៣០នាទីរសៀល។** កិច្ចប្រជុំនេះនឹងធ្វើឡើងដោយអនុវត្តនូវវិធានការណ៍រក្សាគម្លាតសុវត្ថិភាព និងមានការវាស់កំដៅដល់អ្នកចូលរួមទាំងអស់ផងដែរ។

របៀបវារៈ នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

| ម៉ោង | របៀបវារៈ |
|---|---|
| | **បើកកិច្ចប្រជុំ** |
| ១៣:០០ | ១. ការចុះឈ្មោះរបស់ភាគហ៊ុនិក |
| ១៤:៣០ | ២. ការណែនាំសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល |
| ១៤:៣៥ | ៣. មតិស្វាគមន៍របស់ប្រធានមហាសន្និបាត |
| ១៤:៤០ | ៤. ការអនុម័តរបៀបវារៈនៃកិច្ចប្រជុំ និងបទបង្ហាញអំពីដំណើរការនៃការបោះឆ្នោត |
| | **បញ្ហាដែលត្រូវសម្រេច** |
| ១៤:៥០ | ៥. ការអនុម័តការផ្លាស់ប្តូរស្លាកសញ្ញាធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ១៥:០០ | ៦. ការអនុម័តការវិនិយោគរបស់អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ នៅក្នុងវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា |
| ១៥:១៥ | ៧. ការអនុម័ត ស្តីពីការដកការវិនិយោគរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅស្ថាប័ន មីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា |
| ១៥:២៥ | ៨. ការអនុម័តតែងតាំងលោក Albertus Bruggink មកពីស្ថាប័ន ORIX ជាអភិបាលថ្មីនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Ryoji Nishimura |
| ១៥:៣០ | ៩. ការអនុម័ត និងការទទួលស្គាល់ការចូលនិវត្តន៍របស់អភិបាលដែលតែងតាំងដោយធនាគារ Triodos នៅធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ១៥:៣៥ | ១០. ការអនុម័តតែងតាំងអភិបាលថ្មីនៅធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ១៥:៤០ | ១១. ការអនុម័ត និងទទួលស្គាល់ការតែងតាំង លោក Hideomi Shigematsu មកពីស្ថាប័ន SMBC ជាតំណាងភាគហ៊ុនិកថ្មីនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Yuichi Nishimura |
| ១៥:៤៥ | ១២. ការអនុម័តការកែប្រែលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ១៦:០០ | ១៣. ការអនុម័តតែងតាំងសវនករឯករាជ្យប្រចាំធនាគារ សម្រាប់ឆ្នាំ២០២១ |

| | |
|---|---|
| *សម្រាក១៥នាទី* | |
| បញ្ហាដែលត្រូវពិភាក្សា | |
| ១៦:៣០ | ១៤. ផ្សេងៗ |
| ១៦:៣៥ | ១៥. ប្រកាសលទ្ធផលនៃការបោះឆ្នោត |
| ១៨:០០ | ១៦. មតិបិទកម្មវិធី |

ភាគហ៊ុនិក ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនៅ**កាលបរិច្ឆេទកំណត់ទុក ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០** នឹងទទួលបានលិខិតអញ្ជើញតាមរយៈមធ្យោបាយអេឡិចត្រូនិក ឬតាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ បន្ទាប់ពីទទួលបានលិខិតអញ្ជើញ ភាគហ៊ុនិកត្រូវឆ្លើយតបបញ្ជាក់ការចូលរួមមហាសន្និបាតភាគហ៊ុនិក ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី តាមមធ្យោបាយអេឡិចត្រូនិក ឬតាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី **ចាប់ពីថ្ងៃទី២៦ ខែតុលា ដល់ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០។**

ភាគហ៊ុនិកអាចផ្តល់សិទ្ធិប្រទានទៅអ្នកតំណាងណាម្នាក់ឲ្យចូលរួមប្រជុំ និងបោះឆ្នោតជំនួស ក្នុងករណីដែលភាគហ៊ុនិកមិនអាចចូលរួមកិច្ចប្រជុំដោយខ្លួនឯងបាន។ លិខិតប្រគល់សិទ្ធិត្រូវបានផ្ញើជូនភាគហ៊ុនិកជាមួយគ្នានឹងសេចក្តីជូនដំណឹង ស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។ ភាគហ៊ុនិក ឬអ្នកតំណាងត្រូវផ្តល់លិខិតប្រគល់សិទ្ធិជូនធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈមធ្យោបាយអេឡិចត្រូនិក ឬភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី **យ៉ាងយូរត្រឹមថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០។**

ភាគហ៊ុនិកនឹងត្រូវចាត់ទុកថាបានបោះបង់សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក ប្រសិនបើមិនបានបញ្ជាក់ការចូលរួម ឬមិនផ្តល់លិខិតប្រគល់សិទ្ធិជូនធនាគារ ឬភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រតាមពេលកំណត់ខាងលើ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដូចខាងក្រោម៖

- **លោក លឹម អាន** ប្រធានផ្នែកប្រតិបត្តិការ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់
    - ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
    - អ៊ីម៉ែល: lim.an@acledabank.com.kh
- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់
    - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
    - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណិបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់
    - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
    - អ៊ីម៉ែល: op.rtp@acledabank.com.kh

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

អេស៊ីលីដា ACLEDA ACLEDA Bank Plc.